# ពិធីប្រុងពលី

"ប្រុងពលី" ជាកិច្ចមួយដ៏សំខាន់ដែលខ្មែរតែងតែរៀបចំធ្វើដំបូងគេនៅគ្រប់ពិធីធំៗនៅក្នុងជំនឿ និងទំនៀមទម្លាប់ខ្មែរ។ "ប្រុង" មានន័យដូចនឹង"រៀបចំ" ដែរ ឧទាហរណ៍អ្នកស្រុកនៅអង្គរច្រើននិយាយ"ប្រុងម៉ោងប៉ុន្មាន? (រៀបចំធ្វើម៉ោងប៉ុន្មាន? )" រីឯ"ពលី" មានន័យថា"ការបូជា, ពលិកម្ម" និយាយឲ្យងាយយល់ គឺយើងត្រូវខាតបង់អ្វីមួយដើម្បីទៅដល់ទិសដៅថ្មីមួយ។

ធម្មតាកិច្ចនេះដែលត្រឹមត្រូវពិតប្រាកដនោះ គឺរៀបចំនៅចន្លោះពេលថ្ងៃ និងយប់ (ព្រលប់) ប៉ុន្តែដោយសារកិច្ចរៀបចំពេលយប់ ងងឹតពិបាក (ជាពិសេសអ្នកស្រុកខាងជើង, អ្នកអង្គរ) រៀបចំនៅចុងរសៀល (ខ្ទង់ម៉ោងបួនរសៀល)។ បើមានកិច្ចផ្សេងច្រើនទៀតដែលត្រូវធ្វើយ៉ាងហោចណាស់ត្រូវតែរៀបចំនៅពេលរសៀល មិនអាចធ្វើនៅពេលព្រឹកបានជាដាច់ខាត។ មូលហេតុដែលត្រូវរៀបចំនៅជិតយប់ ពីព្រោះកិច្ចនេះ គឺសំដៅលើនិមិត្តរូប"បូជាមនុស្ស"។ តាមធម្មតាគេសម្លាប់ស្រី ពីព្រោះស្រីមានអំណាចអស្ចារ្យម្យ៉ាងនៅក្នុងខ្លួន។ ពេលខ្លះគេកប់មនុស្សស្រីជាពិសេសស្រីដែលមានផ្ទៃពោះ ។ ប៉ុន្តែវាគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ពេលដែលរៀបកិច្ចគេចេះតែនិយាយឧបកិច្ចថាដូច្នោះ។

បើពិធីណាដែលធំ មានទង់ (កិច្ចលើកទង់)។ កិច្ចប្រុងពលី និងលើកទង់មានទំនាក់ទំនងគ្នា មានន័យថា"ស្លាប់" និង"រស់" ពោលគឺមួយទៅលើ និងមួយខាងទៅក្រោម។ ទង់គេដាក់នៅទិសឦសាន គេមិនកប់ទៅក្នុងដីទេ ដាក់ឲ្យផុតពីដី សំដៅទៅលើ។ បើបុណ្យសពគេមានដាក់ទង់ ពីព្រោះចង់ឲ្យអ្នកដែលស្លាប់បានទៅលើ។ ធម្មតាពេលដែលលើកទង់ គេធាកហូរខ្លាំងៗណាស់ ជួនកាលមានបាញ់ជាកាំជ្រួចផង (មែនទែនការបាញ់កាំជ្រួច គឺសម្រាប់បុណ្យសពលោកសង្ឃដែលល្បីធំៗ)។

បើនិយាយឲ្យវែងឆ្ងាយបន្តិច ប្រុងពលីមានស្រទាប់ជំនឿបី គឺជំនឿជីវចល ព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា។ ដើមឡើយកិច្ចប្រុងពលីនេះ ពិតប្រាកដ គឺទាក់ទងនឹងជំនឿខ្មែរដែលអ្នកស្រាវជ្រាវហៅថា "ជំនឿជីវចល"។ ដូចដែលបានលើកឡើងខាងលើ ពោលគឺទាក់ទងនឹងការបូជា ពលិកម្ម។ ប៉ុន្តែសព្វថ្ងៃ ហេតុដូចម្ដេចបានជាក្លាយទៅជា "ក្រុងពាលី" ជាពិសេសអ្នកខាងត្បូង។ និយាយនេះពុំមែនថាអ្នកខាងត្បូងខុសទេ មកពីអាចារ្យមិនយល់ច្បាស់អំពីកិច្ចពិធី ហៅ "ក្រុងពាលី" ដូច្នោះ ទៅអ្នកធម្មតាក៏ចេះតែហៅ ក្រុងពាលីតាមដូច្នោះទៅ

អត្ថបទដោយ៖ **លោក លឹម ស្រ៊ូ**

AMS Khmer Civilization

(តាមខ្ញុំដឹងមានវត្តនៅម្តុំភ្នំពេញ អាចារ្យ និងព្រះសង្ឃ ហៅ "ប្រុងពលី" ដែរ។

"ក្រុង" មានន័យថា "ស្ដេច" (ឧ. ព្រះចៅក្រុងកម្ពុជា) រីឯ "ពាលី" គឺទាក់ទងនឹងរឿងទេពកថាព្រហ្មញ្ញសាសនា ដែលព្រះនារាយណ៍ដើរបីជំហ៊ានរំលងភពទាំងបី។ ទេពកថានោះមានយក្សមួយឈ្មោះ"ពាលី" ដើរអួតក្អេងក្អាង ថាខ្លួនខ្លាំង ដល់ភ្នាល់ចាញ់ព្រះនារាយណ៍ទៅអត់ដីនៅ ព្រះនារាយណ៍ក៏ឲ្យទៅនៅក្រោមដី មិនឲ្យនៅជាមួយគេឯង ព្រោះយក្សនោះខូចពេក។ យក្សក្អេងក្អាងនេះមិនល្អ ចុះហេតុអ្វីត្រូវលើកដម្កើង ដល់ទៅរៀបពិធី ហើយចាំបាច់ទៅស្នើសុំធ្វើអ្វី?

ស្រទាប់មួយទៀតទាក់ទងនឹងព្រះពុទ្ធសាសនា។ ស្រទាប់ព្រះពុទ្ធសាសនា គឺ "នាងគង្ហីង"។ នាងគង្ហីង គឺជាដី តែមិនមែនជាទេពថែរក្សាដីទេ គ្រាន់តែគេធ្វើជារូបតំណាងឲ្យទៅជារូបរាងមនុស្ស។ ក្នុងស្រទាប់ជំនឿទាំងបីនេះ បញ្ជាក់ម្តងទៀត គឺការដែលធ្វើទាក់ទងនឹង "ការបូជាពលិកម្ម" ក្នុងជំនឿជីវចលនេះឯងដែលត្រឹមត្រូវ ។



ប្រុងពលីក្នុងពិធីកោរជុក



កិច្ចលើកទង់



ប្រុងពលីនៃពិធីកោរជុកនៅតំបន់អង្គរ

នាងគង្ហីង

អត្ថបទដោយ៖ **លោក លឹម ស្រ៊ូ**